MEKONG RIVER COMMISSION
MRC
FOR SUSTAINABLE DEVELOPMENT

Mekong River Commission Secretariat
P.O. Box 6101, 184 Fa Ngoum Road, Unit 18,
Ban Sithane Neua, Sikhottabong District, Vientiane 01000, Lao PDR
Telephone: (856-21) 263 263 Facsimile: (856-21) 263 264

# ព័ត៌មានសំខាន់ៗ ស្តីពីកិច្ចប្រជុំកំពូលគណៈកម្មការទន្លេមេគង្គលើកទី ៣

*ការពន្លឿនកិច្ចសហប្រតិបត្តិការ ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព ក្រោមប្រធានបទ "ទន្លេមេគង្គតែមួយ ស្មារតីតែមួយ"*

កិច្ចប្រជុំកំពូលគណៈកម្មការទន្លេមេគង្គលើកទី ៣ នឹងត្រូវរៀបចំដោយគណៈកម្មការទន្លេមេគង្គ (MRC) ។ គណៈកម្មការនេះ គឺជាស្ថាប័នមួយមានតួនាទីពិសេសក្នុងការបំពេញការងារ ដើម្បីជំរុញកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ក្នុងការអភិវឌ្ឍ និងការគ្រប់គ្រងធនធានទឹកឆ្លងដែន និងធនធានផ្សេងទៀតនៃតំបន់អាងទន្លេមេគង្គ។ កិច្ចប្រជុំកំពូលនេះ មានការចូលរួមពីនាយករដ្ឋមន្ត្រីនៃប្រទេសជាសមាជិករបស់ MRC គឺប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម ក៏ដូចជាតំណាងថ្នាក់រដ្ឋមន្ត្រីមកពីប្រទេសចិន និងប្រទេសមីយ៉ាន់ម៉ា ដែលជាដៃគូសន្ទនារបស់គណៈកម្មការនេះផងដែរ។

MRC រំពឹងថា កិច្ចប្រជុំនេះនឹងក្លាយជាព្រឹត្តិការណ៍ដ៏វិសេសវិសាលមួយ ដែលនឹងគូសបញ្ជាក់សាជាថ្មីពីតួនាទី ភារកិច្ច និងបេសកកម្មរបស់ MRC និងបន្តជំរុញឱ្យមានកិច្ចពិគ្រោះយោបល់ដោយចំហ និងកិច្ចសហប្រតិបត្តិការក្នុងតំបន់អាងទន្លេនេះ។ ព្រឹត្តិការណ៍នេះមានគោលបំណងជំរុញលើកកម្ពស់កិច្ចខិតខំប្រឹងប្រែងរួមគ្នា ដែលកំពុងបន្តអនុវត្ត ដើម្បីឆ្លើយតបចំពោះបញ្ហាប្រឈមនានា ដែលកំពុងកើតមានឡើង និងច្បាមយកឱកាស ដើម្បីឱ្យតំបន់អាងទន្លេមេគង្គនេះក្លាយជាតំបន់ដែលមានវិបុលភាពផ្នែកសេដ្ឋកិច្ច មានយុត្តិធម៌សង្គម និងមានបរិស្ថានល្អប្រសើរ។

*ពេលវេលា*

- ថ្ងៃទី ២-៣ ខែ មេសា ឆ្នាំ ២០១៨៖ សន្និសីទអន្តរជាតិមុនកិច្ចប្រជុំកំពូល
- ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៨៖ កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីសម្រាប់ត្រៀមកិច្ចប្រជុំកំពូងលើកទី ៣
- ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៨៖ កិច្ចប្រជុំកំពូលគណៈកម្មការទន្លេមេគង្គលើកទី ៣

*អ្នកចូលរួម*

តំណាងជាន់ខ្ពស់បំផុតនៃរដ្ឋាភិបាល មកពីប្រទេសជាសមាជិករបស់ MRC និងដៃគូសន្ទា នឹងចូលរួមក្នុងកិច្ចប្រជុំកំពូល MRC លើកទី៣ នេះ។ សន្និសីទអន្តរជាតិនឹងស្វាគមន៍តំណាងរបស់ MRC និងអ្នកពាក់ព័ន្ធមកពីអង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នសិក្សាស្រាវជ្រាវ វិស័យឯកជន និងអង្គការអាងទន្លេផ្សេងទៀតក្នុងតំបន់នេះ និងទូទាំងពិភពលោក។

*ទីកន្លែង*

មជ្ឈមណ្ឌលសន្និបាត សុខា សៀមរាប ក្នុងខេត្តសៀមរាប ប្រទេសកម្ពុជា

## ប្រវត្តិសង្ខេប

MRC បានរៀបចំកិច្ចប្រជុំកំពូលពីរលើករួចមកហើយ៖ លើកទី ១ ក្នុងឆ្នាំ ២០១០ ដែលមានប្រទេសថៃ ជាម្ចាស់ផ្ទះ ក្នុងខេត្តហួហ៊ីន និងលើកទី ២ កាលពីឆ្នាំ ២០១៤ ធ្វើជាស់ផ្ទះដោយប្រទេសវៀតណាម ក្នុងទីក្រុងហូជីមិញ។

កិច្ចប្រជុំកំពូលលើកទី ១ ត្រូវបានរៀបចំឡើងកាលពីថ្ងៃទី ៥ ខែមេសា ឆ្នាំ ២០១០ ក្នុងឱកាសខួបលើកទី ១៥ នៃការចុះហត្ថលេខា លើកិច្ចព្រមព្រៀងមេគង្គឆ្នាំ ១៩៩៥។ កិច្ចប្រជុំនេះ គឺជាកិច្ចប្រជុំលើកដំបូង ដែលប្រមុខរដ្ឋាភិបាលនៃប្រទេសជាសមាជិកទាំងបួនរបស់ MRC ជួបប្រជុំគ្នា ក្រោមក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការរបស់ MRC។ ក្រៅពីគូសបញ្ជាក់ពីការប្តេជ្ញាចិត្តកម្រិតនយោបាយចំពោះការអនុវត្តកិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ ១៩៩៥ ព្រឹត្តិការណ៍នេះក៏បានដាក់ចេញកំណែទម្រង់ MRC ផងដែរ ក្នុងគោលបំណងពង្រឹងភាពជាម្ចាស់ក្នុងតំបន់ និងសម្រេចឱ្យបាននូវនិរន្តរភាពផ្នែកហិរញ្ញវត្ថុត្រឹមឆ្នាំ ២០៣០។

កិច្ចប្រជុំកំពូល MRC លើកទី១ បានដាក់ចេញនូវសកម្មភាពជាច្រើនរបស់គណៈកម្មការនេះ ក្នុងយុគសម័យនៃការបង្កើនកិច្ចសហប្រតិបត្តិការ ក្នុងការរៀបចំផែនការ និងគ្រប់គ្រងធនធានទឹក ដែលទាមទារឱ្យមានការផ្លាស់ប្តូរឱ្យបានទាន់ពេលវេលា ដោយសារតែការអភិវឌ្ឍយ៉ាងលឿនក្នុងតំបន់អាងទន្លេមេគង្គកាលពីពេលនោះ។ ការដាក់ចេញនូវកិច្ចសហប្រតិបត្តិការនេះ នាំឱ្យមានការផ្តោតការយកចិត្តទុកដាក់លើភាពពឹងអាស្រ័យលើគ្នាទៅវិញទៅមក រវាងវិស័យប្រើប្រាស់ទឹកនានា ដូច្នេះហើយបានជាប្រធានបទសម្រាប់កិច្ចប្រជុំកំពូល MRC លើកទី ២ ផ្តោតជុំវិញបញ្ហាទឹក ស្បៀង និងថាមពល។

កិច្ចប្រជុំកំពូលលើកទី ២ មានគោលបំណងពង្រឹងសមត្ថភាពក្នុងតំបន់អាងទន្លេទាំងមូល ដើម្បីគាំទ្រដល់ការអភិវឌ្ឍប្រកបដោយចីរភាព ខណៈពេលដែលនឹងមានភាពមិនប្រាកដប្រជាជាច្រើននាពេលអនាគត ដូចជា ការប្រែប្រួលអាកាសធាតុ និងហានិភ័យពាក់ព័ន្ធជាដើម។

នៅក្នុងកិច្ចប្រជុំកំពូលលើកទី ២ ក៏មានការសម្រេចចិត្តពន្លឿនការអនុវត្តការសិក្សារបស់ក្រុមប្រឹក្សាគណៈកម្មការទន្លេមេគង្គ ដែលជាការសិក្សាគ្រប់ជ្រុងជ្រោយលើការគ្រប់គ្រង និងការអភិវឌ្ឍប្រកបដោយចីរភាពនៃទន្លេមេគង្គ រួមទាំងលើផលប៉ះពាល់ ដែលបង្កឡើងដោយគម្រោងវារីអគ្គិសនីនៅតាមដងទន្លេមេផងដែរ។ អាទិភាពផ្សេងទៀត ដែលត្រូវបានដាក់ចេញក្នុងព្រឹត្តិការណ៍នេះ រួមមាន ការកែលម្អការអនុវត្តនីតិវិធីរបស់ MRC និងការជំរុញឱ្យមានកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយក្នុងតំបន់អាងទន្លេទាំងមូល ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត។ ដំណើរការវិមជ្ឈការក៏ត្រូវបានបន្តអនុវត្តផងដែរ។

## កិច្ចប្រជុំកំពូលគណៈកម្មការទន្លេមេគង្គលើកទី ៣ នេះនឹងប្រើប្រាស់សមិទ្ធផលដែលសម្រេចបានពីកិច្ចប្រជុំកំពូលទាំងពីរលើកកន្លងមកជាមូលដ្ឋាន

កិច្ចប្រជុំកំពូលទាំងពីរកន្លងមកនេះ មានសារៈសំខាន់ ក្នុងការជួយឱ្យ MRC សម្រេចនូវវឌ្ឍនភាពបន្តទៀត ពោលគឺជួយឱ្យស្ថាប័ននេះក្លាយជាស្ថាប័នដែលមានភាពចាស់ទុំ ជាស្ថាប័ននាំមុខគេក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន និងដាក់ចេញនូវការប្តេជ្ញាចិត្តយ៉ាងមុតមាំ ដើម្បីឈានទៅសម្រេចបេសកកម្មរបស់ខ្លួន។ ជារួម កិច្ចប្រជុំកំពូលទាំងនេះ បានជួយដាក់ចេញនូវមូលដ្ឋានគ្រឹះ ដើម្បីឱ្យមានការងាកចេញពីការរៀបចំផែនការ និងការអនុវត្តការងារនៅតាមប្រទេស និងផ្តោតតាមវិស័យរៀងៗខ្លួនទៅជាការរៀបចំផែនការ និងការគ្រប់គ្រងផ្តោតលើតំបន់អាងទន្លេទាំងមូលប្រកបដោយនិរន្តរភាព។

កិច្ចប្រជុំកំពូល MRC លើកទី ៣ នេះ នឹងយកលទ្ធផលដែលសម្រេចបានកន្លងមកទាំងនេះ មកធ្វើជាមូលដ្ឋានសម្រាប់ការពិភាក្សា ហើយគេរំពឹងថាកិច្ចប្រជុំកំពូលលើកនេះនឹងបន្តពង្រឹង និងពង្រីកកិច្ចខិតខំប្រឹងប្រែងរួមគ្នា ក៏ដូចជាភាពជាដៃគូដែលមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៃអាងទន្លេនេះ។

## ចំណុចសំខាន់ៗ ដែលត្រូវផ្តោតការយកចិត្តទុកដាក់ក្នុងកិច្ចប្រជុំកំពូល MRC លើកទី៣

### ១) ពង្រឹងកិច្ចខិតខំប្រឹងប្រែងរួមគ្នា និងភាពជាដៃគូ

ចំណុចផ្តោតសំខាន់នៃកិច្ចប្រជុំកំពូល MRC លើកទី ៣ គឺការពង្រឹងកិច្ចខិតខំប្រឹងប្រែងរួមគ្នា និងភាពជាដៃគូរវាងប្រទេសជាសមាជិករបស់ MRC និងគ្រប់ដៃគូពាក់ព័ន្ធទាំងអស់។ ខណៈពេលដែលកិច្ចប្រជុំកំពូលមុនៗ នាំមកនូវការលើកកម្ពស់កិច្ចសហប្រតិបត្តិការដោយប្រើប្រាស់អភិក្រមគ្រប់គ្រងធនធានទឹកចម្រុះ (IWRM) ក៏ដូចជា នាំឱ្យមានការគិតគូរលើសពីវិស័យធនធានទឹក ប្រធានបទសំខាន់នៅឆ្នាំនេះទទួលស្គាល់ថា ការអភិវឌ្ឍប្រកបដោយចីរភាព ពឹងអាស្រ័យលើជោគជ័យនៃកិច្ចសហប្រតិបត្តិការរួមគ្នា និងភាពជាដៃគូដែលមានលក្ខណៈបើកចំហ ដែលនេះជាចំណុចពិសេសមួយនៃអត្តសញ្ញាណរបស់ MRC ។ លទ្ធផលរំពឹងទុក ចេញពីកិច្ចប្រជុំកំពូលនេះ រួមមាន ការគូសបញ្ជាក់សាជាថ្មីពីកិច្ចសហប្រតិបត្តិការក្នុងការអនុវត្តគម្រោងរួមគ្នា ការពិនិត្យតាមដានរួមគ្នា និងការអនុវត្តសកម្មភាពរួមគ្នា ព្រមទាំងការបង្កើតនូវភាពជាដៃគូថ្មីៗ ដើម្បីធ្វើឱ្យកាន់តែប្រសើរនូវទំនាក់ទំនងរវាងថ្នាក់តំបន់-ថ្នាក់ជាតិ កិច្ចសហប្រតិបត្តិការឆ្លងដែន និងកិច្ចសហប្រតិបត្តិការជាមួយនឹងដៃគូសន្ទនា ដៃគូអភិវឌ្ឍន៍របស់ MRC និងគំនិតផ្តួចផ្តើមនៅថ្នាក់តំបន់ដទៃទៀត។

### ២) សកម្មភាពរួមគ្នា ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព

ការអភិវឌ្ឍសំខាន់មួយក្នុងសកលលោក ចាប់តាំងពីកិច្ចប្រជុំកំពូល MRC លើកទី ២ គឺការប្តេជ្ញាចិត្តរបស់សកលលោកទាំងមូល ក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) របស់អង្គការសហប្រជាជាតិ។ MRC ទទួលស្គាល់ពីតួនាទីដ៏សំខាន់ ដែលការអភិវឌ្ឍ និងការគ្រប់គ្រងធនធាន

ទឹក និងធនធានពាក់ព័ន្ធ មានចំពោះការសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពក្នុងតំបន់អាងទន្លេមេគង្គ ហើយ MRC មានគោលបំណងរួមចំណែកដោយផ្ទាល់ និងដោយប្រយោលក្នុងការសម្រេចគោលដៅទាំងនេះ។ បើទោះបីជា MRC ផ្តោតជាសំខាន់លើគោលដៅទី ៦ ស្តីពីទឹកយ៉ាងណាក៏ដោយ មានគោលដៅ SDG យ៉ាងហោចណាស់ចំនួន ១០ ក្នុងចំណោមគោលដៅ SDG ទាំង ១៧ ដែលមានភាពពាក់ព័ន្ធខ្លាំងជាមួយនឹង MRC ដោយសារតែការប្តេជ្ញាចិត្តដ៏មុតមាំរបស់ស្ថាប័ននេះចំពោះបញ្ហាទឹក ស្បៀង ថាមពល និងការអភិវឌ្ឍប្រកបដោយចីរភាព។ MRC ជាស្ថាប័នពិសេស ដែលអាចផ្តល់ការគាំទ្រដល់ការធ្វើសេចក្តីសម្រេចចិត្ត និងដល់ក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការសម្រាប់ប្រទេសជាសមាជិក MRC ខណៈពេលដែលប្រទេសទាំងនេះធ្វើការកំណត់ពីជម្រើសពាក់ព័ន្ធនឹងភាពទ្វេគ្រោះ (ការខាតបង់និងអត្ថប្រយោជន៍ដែលទទួលបាន) និងការអនុវត្តសកម្មភាពរួមគ្នា ដើម្បីឈានទៅសម្រេចគោលដៅ SDG ទាំងនេះ។

## ៣) ការប្រើប្រាស់លទ្ធផលដែលបានពីការសិក្សារបស់ក្រុមប្រឹក្សា (Council Study)

ចាប់តាំងពីកិច្ចប្រជុំកំពូល MRC លើកទី២រួចមក MRC បានធ្វើការស្រាវជ្រាវពីកាលានុវត្តភាព និងបញ្ហាប្រឈមក្នុងតំបន់អាងទន្លេទាំងមូល តាមរយៈការសិក្សា និងការវាយតម្លៃរបស់ខ្លួន ដែលការសិក្សា និងការវាយតម្លៃសំខាន់ជាងគេ គឺការសិក្សាស្តីពីការគ្រប់គ្រង និងការអភិវឌ្ឍតំបន់អាងទន្លេមេគង្គ ប្រកបដោយនិរន្តរភាព (ដែលហៅកាត់ថា ការសិក្សារបស់ក្រុមប្រឹក្សា)។ អ្នកពាក់ព័ន្ធដែលចូលរួមក្នុងសន្និសីទអន្តរជាតិមុនកិច្ចប្រជុំកំពូលនេះ នឹងត្រូវបានអញ្ជើញឱ្យផ្តល់ជាគំនិត និងធ្វើការឆ្លុះបញ្ចាំងលើលទ្ធផលរកឃើញសំខាន់ៗនៃការសិក្សានេះ។ គំនិតយោបល់ទាំងនេះ នឹងជួយឱ្យ MRC និងប្រទេសជាសមាជិកធ្វើការពិចារណាយកលទ្ធផល ដែលសម្រេចបាននេះ ទៅប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការរៀបចំផែនការនៅថ្នាក់តំបន់ និងនៅថ្នាក់ជាតិ។ ការសិក្សានេះក៏មានភាពពាក់ព័ន្ធសម្រាប់យុទ្ធសាស្ត្រស្តីពីវារីអគ្គិសនីប្រកបដោយចីរភាព ជាយុទ្ធសាស្ត្រថ្មី ដែលនឹងត្រូវបោះពុម្ពផ្សាយក្នុងឆ្នាំ ២០១៩ និងយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍតំបន់អាងទន្លេ ដែលនឹងត្រូវបោះពុម្ពផ្សាយក្នុងឆ្នាំ ២០២០។

## ៤) ការពង្រឹងតួនាទី និងសមត្ថភាពរបស់គណៈកម្មការទន្លេមេគង្គ

ការពង្រឹងកិច្ចសហប្រតិបត្តិការ ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពនៃតំបន់អាងទន្លេមេគង្គ តម្រូវឱ្យ MRC បន្តពង្រឹងតួនាទី និងសមត្ថភាពរបស់ខ្លួន។ ជាមួយនឹងការបន្តតួនាទី ភារកិច្ច និងបេសកកម្ម ដែលត្រូវបានកំណត់ដោយថ្នាក់ដឹកនាំនយោបាយកម្រិតខ្ពស់នៃប្រទេសជាសមាជិក MRC នឹងពង្រឹងតួនាទីរបស់ខ្លួនក្នុងនាមជាមជ្ឈមណ្ឌលចំណេះដឹង និងជាវេទិកាការទូតផ្នែកទឹក ក៏ដូចជាបំពេញតួនាទីកាន់តែសកម្មបន្ថែមទៀត ក្នុងនាមជាអ្នកសម្របសម្រួលអព្យាក្រឹត្យ ដើម្បីធ្វើឱ្យមានតុល្យភាពរវាងផលប្រយោជន៍របស់ប្រទេសនីមួយៗ និង ផលប្រយោជន៍សម្រាប់តំបន់អាងទន្លេ

ទាំងមូល តុល្យភាពរវាងប្រទេសមួយ និងប្រទេសមួយទៀត និងតុល្យភាពរវាងតម្រូវការនៃការអភិវឌ្ឍ និងចីរភាពបរិស្ថាន។

## ជំហានបន្ទាប់

កិច្ចប្រជុំកំពូល MRC លើកទី ៣ នេះ នឹងបញ្ចប់ទៅជាមួយនឹងការដាក់ចេញនូវសេចក្តីប្រកាសសៀមរាប ដែលនឹងកំណត់ពីអាទិភាពរបស់ MRC សម្រាប់រយៈពេលបួនឆ្នាំខាងមុខទៀត រហូតដល់កិច្ចប្រជុំកំពូលលើកទី ៤ ក្នុងឆ្នាំ ២០២២ ដែលនឹងធ្វើឡើងនៅប្រទេសឡាវ។ សកម្មភាពសំខាន់ៗក៏នឹងត្រូវដាក់ចេញក្នុងសេចក្តីប្រកាសនេះផងដែរ។

## អំពីគណៈកម្មការទន្លេមេគង្គ

គណៈកម្មការទន្លេមេគង្គ (MRC) គឺជាស្ថាប័នអន្តររដ្ឋាភិបាល ដែលទទួលខុសត្រូវលើការជំរុញកិច្ចសហប្រតិបត្តិការស្តីពីការគ្រប់គ្រងតំបន់អាងទន្លេមេគង្គប្រកបដោយចីរភាព។ សមាជិករបស់គណៈកម្មការនេះរួមមានប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។ គណៈកម្មការនេះបំពេញតួនាទីជាវេទិកាថ្នាក់តំបន់សម្រាប់ការទូតផ្នែកទឹក ក៏ដូចជាមជ្ឈមណ្ឌលចំណេះដឹង ស្តីពីការគ្រប់គ្រងធនធានទឹក ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពនៃតំបន់នេះ។ MRC មិនមែនជាស្ថាប័នដែលមានសិទ្ធិអំណាចខ្ពស់ជាងថ្នាក់ជាតិ ឬជាស្ថាប័ននិយតកម្មនោះឡើយ។ គណៈកម្មការនេះធ្វើការងារពាក់ព័ន្ធនឹងគ្រប់វិស័យទាំងអស់ ដើម្បីសម្រេចគោលបំណងច្រើនយ៉ាង ដូចជា ការធានានិរន្តរភាពធនធាននេសាទ ការជំរុញលើកកម្ពស់ការអភិវឌ្ឍវារីអគ្គិសនី ប្រកបដោយចីរភាព ការកំណត់ឱកាសសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម ការរក្សានូវសេរីភាពនៃការធ្វើនាវាចរណ៍ ការកែលម្អការគ្រប់គ្រងស្បៀង និងការរក្សាការពារប្រព័ន្ធអេកូឡូហ្ស៊ីសំខាន់ៗ។ ផលប៉ះពាល់ដែលបង្កឡើងដោយគ្រោះទឹកជំនន់ធ្ងន់ធ្ងរ គ្រោះរាំងស្ងួត ដែលអូសបន្លាយពេលយូរ និងការកើនឡើងនៃកម្ពស់ទឹកសមុទ្រពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ នឹងដាក់សម្ពាធបន្ថែមទៀត មកលើបញ្ហាខាងលើនេះ។

*សូមស្វែងរកព័ត៌មានបន្ថែមតាមរយៈគេហទំព័រ www.mrcsummit.org*

###